ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
***Nation - Religion - King***

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
លេខ ៣៧៥ ព.ណ.ឋ.ល.ប្រក

## ប្រកាស
## ស្តីពីការកែសម្រួលប្រកាសលេខ ១៦៥ MOC/SM2010 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្មជូនដល់ ក្រុង ស្រុក ខណ្ឌគោលដៅ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
-បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
-បានឃើញសេចក្តីសម្រេចលេខ១២ សសរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌគោលដៅ
-យោងប្រកាសលេខ៩២៨ ប្រកចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ
-យោងប្រកាសរួមលេខ១៦៨៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
-តាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១ ៖**

ត្រូវបានធ្វើប្រតិភូកម្មការងារគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ជូនដល់ក្រុង ស្រុក ខណ្ឌគោលដៅ ដែលមានការិយាល័យច្រកចេញចូលតែមួយ ដើម្បីអនុវត្តនូវវិធាន និងបទប្បញ្ញត្តិក្នុងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ជូនដល់អាជីវករជារូបវន្តបុគ្គល ដែលមិនជាប់ពន្ធលើប្រាក់ចំណេញ។



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥) -២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

**ប្រការ ២ ៖**

មន្ត្រីជំនាញទទួលបន្ទុកការងារគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម គឺជាមន្ត្រីរបស់មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្តសាមី ដែលប្រចាំការនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវសម្របសម្រួលរាល់ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម។

**ប្រការ ៣ ៖**

លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មមានសុពលភាពរយៈពេល ០១ឆ្នាំ។

**ប្រការ ៤ ៖**

អាជីវករ សេវាករ ពាណិជ្ជករ ដែលសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ត្រូវមានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនរដ្ឋចំនួន ២៥,០០០រៀល (ម្ភៃប្រាំពាន់) នៅ ក្រុង ស្រុក ខណ្ឌគោលដៅ ដោយឡែកនៅរាជធានីភ្នំពេញដែលមានទីតាំងប្រកបអាជីវកម្មទំហំលើសពី៥ម៉ែត្រការ៉េ ជាសមត្ថកិច្ចរបស់មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ។

**ប្រការ ៥ ៖**

មន្ត្រីជំនាញទទួលបន្ទុកការងារគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លង នៃលិខិតអនុញ្ញាតខាងលើរៀងរាល់ខែ ត្រីមាស ឆមាស ឆ្នាំ ផ្ញើជូនមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ឲ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំត្រូវផ្ញើមកឲ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

**ប្រការ៦៖**

អាជីវករ ដែលប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ដោយគ្មានលិខិតអនុញ្ញាត ត្រូវចាត់ទុកថា ជាការប្រកបអាជីវកម្មមិនស្របច្បាប់ ហើយត្រូវទទួលវិធានការដូចខាងក្រោម៖

-វិធានការទី១ ៖ ធ្វើការណែនាំឲ្យមកសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម
-វិធានការទី២ ៖ ព្រមានជាលាយលក្ខអក្សរ
-វិធានការទី៣ ៖ ផ្អាកសកម្មភាពអាជីវកម្មជាបណ្តោះអាសន្ន

**ប្រការ ៧ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨ ៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

Chanthol Sun

**ស៊ុន ចាន់ថុល**

<u>ចម្លងជូន៖</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អង្គភាពប្រឆាំងអំពើពុករលួយ
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី-ខេត្ត (សហការណ៍អនុវត្ត)
-ក្រុង ស្រុក ខណ្ឌគោលដៅ
-ដូចប្រការ ៨ (ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ